# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សេចក្ដីប្រកាសព័ត៌មាន

ដើម្បីធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋលើបញ្ហាដីធ្លី ការលើកកម្ពស់កម្រិតជីវភាព ការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ សន្តិសុខស្បៀង និងភាពសុខដុមនៃសង្គម រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ជាសេនាធិការ បានខិតខំរៀបចំនូវបទដ្ឋានគតិយុត្តសមស្រប និងដាក់ចេញនូវផែនការសកម្មភាពជាក់ស្ដែងជំរុញការចុះបញ្ជីដីធ្លីទូទាំងប្រទេស និងយន្តការនៃការដោះស្រាយវិវាទដីធ្លីជូនប្រជាពលរដ្ឋ រួមមាន (១)គណៈកម្មការសុរិយោដីថ្នាក់ជាតិ-ថ្នាក់ខេត្ត (២)អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, (៣) យន្តការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ និង (៤)យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយឈរលើគោលការណ៍ច្បាប់ជាធរមាន មិនមានការបង្ខិតបង្ខំគំរាមកំហែង ឬបំភិតបំភ័យត្រូវភាគីណាមួយឡើយ។

ជាលទ្ធផលគិតត្រឹមដំណាច់ខែមេសា ឆ្នាំ២០១៩នេះ (១)ការចុះបញ្ជីដីទូទាំងប្រទេសសម្រេចបានប្រមាណ ៥,២ លានក្បាលដី ស្មើនឹង ៧៤% នៃចំនួនក្បាលដីប៉ាន់ស្មានសរុប ៧ លានក្បាលដី ក្នុងនោះ ចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធបាន ៤,៦ លានក្បាលដី ចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំបាន ៦ សែនក្បាលដី។ (២)ក្នុងការងារដោះស្រាយវិវាទដីធ្លី ក្រសួងទទួលបានពាក្យបណ្ដឹង ១០ ០៧៨ ករណី ក្នុងនោះបានដោះស្រាយបញ្ចប់ ៨ ០៦២ ករណី និងកំពុងដោះស្រាយ ២ ០១៦ ករណី។ (៣)ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចបាន ២៤ សហគមន៍ ស្មើនឹង ៦៨៤ ក្បាលដី ។ តាមផែនការ ការចុះបញ្ជីដីទូទាំងប្រទេស រួមទាំងចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចនឹងឈានទៅសម្រេចបាន ១០០ % នៅត្រឹមឆ្នាំ ២០២១។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១៣ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែឧសភា ឆ្នាំ ២០១៩